00223671

D99/3/5

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**Declassified to Public**
**06 September 2012**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ១១ កញ្ញា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / SEP / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Tuy

# សម្ងាត់

## សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំការអនុញ្ញាតពិនិត្យសំណុំរឿង

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ជនត្រូវចោទ**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត
Silke STUDZINSKY
គីម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" ទទួលបានលិខិតរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ("សំណើ") ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ ដោយក្នុងនោះធ្វើការស្នើសុំការអនុញ្ញាតឱ្យចៅក្រម និងបុគ្គលិកជំនួយផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូង មានលទ្ធភាពពិនិត្យសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ អវតក/កសចស តាមប្រព័ន្ធស្រាវជ្រាវអេឡិចត្រូនិចរបស់ អ.វ.ត.ក គឺ ZyIMAGE ។

២. នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ដល់ភាគី ដោយធ្វើការអញ្ជើញពួកគេ ឱ្យដាក់សេចក្តីជំទាស់ចំពោះសំណើនេះ (ដែលសំណើមានភ្ជាប់មកជាមួយសេចក្តីបង្គាប់) ត្រឹមថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨។

៣. នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានតប ដោយសង្កេតឃើញថា សហព្រះរាជអាជ្ញាគ្មានការជំទាស់ចំពោះការអនុញ្ញាតឱ្យពិនិត្យសំណុំរឿងនេះឡើយ។

៤. នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ សហមេធាវីជនត្រូវចោទបានធ្វើការលើកឡើងដូចគ្នាដែរថា សហមេធាវីមិនមានការជំទាស់ទៅនឹងការអនុញ្ញាតឱ្យពិនិត្យសំណុំរឿងនេះដែរ។

៥. អង្គបុរេជំនុំជម្រះ មិនទទួលបានសេចក្តីសង្កេតពីដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស ("បណ្តឹងឧទ្ធរណ៍")។ ដូច្នេះ សំណុំរឿងនេះបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៦៩(១)នៃវិធានផ្ទៃក្នុង។

៧. អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា "ការចូលមើលសំណុំរឿងនេះមិនមែនជាទទួលសំណុំរឿងជាលក្ខណៈផ្លូវការនោះទេ រហូតដល់ពេលមានការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយនេះសិន" ហើយ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់អំពីលក្ខណៈសម្ងាត់នៃសំណុំរឿងនេះ នៅក្នុងដំណាក់ការនីតិវិធីនាពេលបច្ចុប្បន្ននេះ។

៨ ដោយពិចារណាលើសេចក្តីសង្កេតរបស់ភាគី និងលក្ខណៈនៃបញ្ហានេះនៅក្នុងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា ការផ្តល់លទ្ធភាពពិនិត្យសំណុំរឿង អាចអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងចាប់ផ្តើមការងាររៀបចំបឋមរបស់ខ្លួន ហើយអាចជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការធានាដល់ការជំនុំជម្រះឱ្យដំណើរការទៅប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

(១) អនុញ្ញាតឱ្យចៅក្រម និងបុគ្គលិកជំនួយផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពពិនិត្យសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ អវតក/កសចស តាមប្រព័ន្ធស្រាវជ្រាវអេឡិចត្រូនិចរបស់អវតកគឺ ZyIMAGE។ និង

(២) បង្គាប់ផ្នែកគ្រប់គ្រងតុលាការ ឱ្យជួយសម្រួលការងារនេះ។

ភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន